**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
**លេខ: ០៥៣/២១ .........អអរ**

## សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពីលទ្ធផលនៃសន្និសីទសារព័ត៌មាន ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១

ព្រឹកថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្ដីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្តរបស់ខេត្តកោះកុង»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម កាយ សំរួម ប្រធានក្រុមប្រឹក្សាខេត្តកោះកុង**
- **លោក សុខ សុទ្ធី អភិបាលរងខេត្តកោះកុង**
- **លោក លឹម ឌី ចៅសង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់។

### I. សេចក្ដីផ្ដើម

ខេត្តកោះកុងមានផ្ទៃដីសរុប ១០.០៤៥,៥៨ គីឡូម៉ែត្រការ៉េ ចែកចេញជាក្រុង១ មាន០៣សង្កាត់ ៦ស្រុក មាន២៦ឃុំ និងមានភូមិសរុបចំនួន១១៩ភូមិ មានប្រជាជនសរុប ១៣៦.៣២០នាក់ ស្រី៦៧.៥៨៤នាក់ ដែលមានវិស័យសេដ្ឋកិច្ចសំខាន់ៗ ៣រួមមាន៖ វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម។

## II. វឌ្ឍនភាពការងារ

វឌ្ឍនភាពការងារដែលខេត្តសម្រេចបានរួមមាន៖

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្តបានខិតខំបំពេញតួនាទី ភារកិច្ច និងមុខងាររបស់ខ្លួនដោយសម្រេចបាននូវលទ្ធផលដូចខាងក្រោម៖

- បានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត នៅតាមក្រុង ស្រុក ៖ នៅក្នុងឆ្នាំ២០១៩ បានទទួលសំណើ និងសំណូមពរ ចំនួន១២១ករណី និងបានធ្វើការដោះស្រាយបាន ចំនួន ១០៨ករណី។ ក្នុងឆ្នាំ២០២០ បានទទួលសំណើ និងសំណូមពរ ចំនួន១១០ករណី និងដោះស្រាយបាន ចំនួន១០០ ករណី។
- ចេញសេចក្ដីសម្រេចការបែងចែកតួនាទី ភារកិច្ចជូនសមាជិកក្រុមប្រឹក្សាខេត្តឱ្យចុះសហការជាមួយរដ្ឋបាលក្រុង ស្រុកក្នុងការប្រមូលរាល់ព័ត៌មាន សំណើ និងសំណូមពរនានា របស់ក្រុមប្រឹក្សាក្រុង ស្រុក និងឃុំ សង្កាត់ ដើម្បីរៀបចំជារបាយការណ៍សម្រាប់ដាក់ចូល ក្នុងកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត ដើម្បីដោះស្រាយ និងឆ្លើយតបតម្រូវការប្រជាពលរដ្ឋ។
- ការងារប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ ១៩៖ រៀបចំឱ្យមានមណ្ឌលចត្តាឡីស័កនៅតាមក្រុង ស្រុក, ចុះអប់រំផ្សព្វផ្សាយអំពីវិធានការការពារ បង្ការការឆ្លងជំងឺកូវីដ-១៩ ត្រួតពិនិត្យទីតាំងពិនិត្យសុខភាពនៅតាមក្រុងស្រុក ច្រកទ្វារព្រំដែន អន្តរជាតិចាំយាម និងបានចូលរួមបរិច្ចាគថវិកាជាមួយរាជរដ្ឋាភិបាល ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងសម្រាប់ទិញវ៉ាក់សាំងការពារជំងឺកូវីដ-១៩ ព្រមទាំងបានឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងជនងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ចំនួន ៩.១១៤គ្រួសារ។

### ❖ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ

- ផ្នែកហេដ្ឋារចនាសម្ព័ន្ធ៖ ផ្លូវបេតុងអាមេ ទូទាំងសង្កាត់បានប្រវែងសរុប ៣,៣៨២ម៉ែត្រ, បានដាក់លូមូលដោះទឹក១កន្លែង ប្រវែង៨៣ម៉ែត្រ បានស្ថាបប្រឡាយ ១កន្លែង ប្រវែង ៣៥ម៉ែត្រ។
- បានចូលរួមវគ្គបណ្ដុះបណ្ដាល អំពីការបង្ការគ្រោះធម្មជាតិ ចំនួន ០៤វគ្គ
- បានចូលរួមធ្វើអនាម័យជាសាធារណៈ ក្នុងការលើកកម្ពស់បរិស្ថាន ចំនួន ១៨លើក
- បានចូលរួមផ្សព្វផ្សាយអំពីការថែទាំ ការបង្ការ និងការអភិរក្ស ធនធានសមុទ្រ ចំនួន ០៥លើក
- បានចូលរួមវគ្គផ្សព្វផ្សាយស្ដីពីការអភិរក្សត្រីកាម៉ុង ចំនួន ០២លើក

- បានចូលរួមផ្សព្វផ្សាយ ការធ្វើអនាម័យដល់ប្រជាជនតាមគេហដ្ឋាន ដើម្បីឱ្យចេះវែកសំរាមសំណល់រឹង រាវ បានចំនួន ២៨លើក។
- បានធ្វើកិច្ចសហប្រតិបត្តិការ ជាមួយក្រុមប្រឹក្សាសង្កាត់ ក្នុងការផ្តល់សេវាសាធារណៈ ការផ្តល់ផលប្រយោជន៍នានា ពីការអភិវឌ្ឍ និងការផ្តល់កិច្ចគាំពារផ្នែកសង្គមប្រកបដោយសមធម៌ ដល់គ្រប់ប្រជាពលរដ្ឋ។
- បានគាំទ្រ និងលើកទឹកចិត្តដល់ការបង្កើត និងដំណើរការសហគមន៍នៅមូលដ្ឋាន ព្រមទាំងគាំទ្រដល់សកម្មភាពនានា របស់អង្គការសង្គមស៊ីវិល និងផ្នែកឯកជននានា ដែលប្រតិបត្តិការដើម្បីបំរើការផ្តល់សេវា និងអភិវឌ្ឍន៍នៅក្នុងសង្កាត់។

## III. ទិសដៅការងារបន្ត

### ❖ ក្រុមប្រឹក្សាខេត្ត

- បន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត និងរៀបចំផែនការចុះគាំទ្រនៅមូលដ្ឋានដើម្បីប្រមូលតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងការអនុវត្តនូវមុខងារជាជម្រើសរបស់ក្រុមប្រឹក្សា។
- ជំរុញ និងគាំទ្រការអនុវត្តក្របខណ្ឌការងារគណនេយ្យភាពសង្គម និងយន្តការច្រកចេញចូលតែមួយ សំដៅបង្វិតសេវាសាធារណៈឱ្យបានគៀកជិតប្រជាពលរដ្ឋនៅមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។
- បន្តពង្រឹងគោលនយោបាយរៀបចំផែនការអភិវឌ្ឍ និងការកសាងកម្មវិធីវិនិយោគ ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ឱ្យមានសង្គតិភាព និងការរៀបចំយុទ្ធសាស្ត្រថវិកា ឱ្យបានសមស្របទៅតម្រូវការក្នុងការអភិវឌ្ឍ។
- បន្តគាំទ្រ អនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលខេត្ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍ និងការផ្តល់សេវានៅមូលដ្ឋាន។
- បន្តពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា និងជម្រុញដល់គណៈអភិបាល អនុវត្តតួនាទី ភារកិច្ច ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនានា។
- បន្តចូលរួមសកម្មភាពនានាក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩។

- ❖ **សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ៖**

- ពង្រឹងការប្រើប្រាស់ផ្លូវ ប្រកបដោយប្រសិទ្ធិភាព ទប់ស្កាត់ការផ្ទុកលើសទំងន់ របស់យានយន្ត គ្រប់ប្រភេទ លើផ្លូវដែលគ្រប់គ្រងដោយសង្កាត់។
- ខិតខំបំផុសប្រជាជន សប្បុរសជន អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា
- បន្តចូលរួមក្នុងដំណើរការអភិវឌ្ឍ និងគ្រប់គ្រងផ្លូវអោយកាន់តែមានលក្ខណៈល្អប្រសើរឡើង ពិសេសកែលំអរដោជំហានៗ នូវផ្លូវលំពីក្រាលគ្រួសក្រហមទៅជាផ្លូវក្រាលបេតុងអាមេ។
- ជំរុញការចូលរួមពីស័យឯកជនក្នុងការអភិវឌ្ឍ និងថែទាំផ្លូវថ្នល់ព្រមទាំងការផ្តល់សេវាកម្ម ដឹកជញ្ជូននៅក្នុងទីក្រុង ទីប្រជុំជន និងសង្កាត់។
- ជំរុញការផ្សព្វផ្សាយនូវច្បាប់ចរាចរណ៍ផ្លូវគោក ឱ្យបានទូលំទូលាយដល់ប្រជាជនអំពីសុវត្ថិភាព នៃការដឹកជញ្ជូន និងពង្រឹងសុវត្ថិភាពចរាចរណ៍។
- ជំរុញការផ្សព្វផ្សាយការធ្វើអនាម័យ ដើម្បីធានាបាននូវសុខមាលភាពល្អ និងបរិស្ថានល្អ ក៏ដូចជាលើកកម្ពស់សោភ័ណ្ឌភាព និងទេសចរណ៍ផងដែរ។

## IV. សម្គាល់

ក្រុមប្រឹក្សា និងគណៈអភិបាលខេត្តកោះកុង មានចក្ខុវិស័យច្បាស់លាស់ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ដែលធ្វើឱ្យប្រជាពលរដ្ឋរស់នៅបានសុខសាន្ត មានជីវភាពធូធារតាមរយៈកិច្ចការសំខាន់ៗ ដូចជា ការអភិវឌ្ឍធនធានមនុស្ស ការពង្រឹងការដឹកនាំ ការអនុវត្តតួនាទី ភារកិច្ច ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ការផ្លាស់ប្តូរទស្សនៈ ឥរិយាបថរបស់ថ្នាក់ដឹកនាំ និងមន្ត្រីនៅក្រោមឱវាទ ដោយបានខិតខំផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងការអភិវឌ្ឍប្រកបដោយសមធម៌ និងចីរភាព។

ថ្ងៃព្រហស្បតិ៍ ៧រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១